ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2015, 10:08
CMS/CFO: Sann Rada

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំឲ្យយក និង ដាក់នៅក្នុងសំណុំរឿងនូវសម្ភារៈឯកសាររបស់ អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក.**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

លោក មាស មុត តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្ដី") អនុលោមតាមវិធាន ២១ វិធាន ៥៥(១០) និង វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង ("វិធាន") តាមរយៈនេះ ស្នើសហចៅក្រមស៊ើបអង្កេត ឲ្យយក និង ដាក់ទៅក្នុងសំណុំរឿងនូវសម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ ("អ.ស.ប.") និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការចរចាដើម្បីបង្កើត អ.វ.ត.ក. និង សេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ សំណើនេះត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះសម្ភារៈឯកសារនេះនឹងជួយក្នុងការសម្រេចថា តើពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* គឺជាការដាក់កម្រិតផ្នែកយុត្តាធិការលើ អ.វ.ត.ក. ឬយ៉ាងណា និង អត្ថន័យនៃពាក្យទាំងនោះ។ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចត្រូវគោរពតាម និង អាចងាកចេញពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ពាក្យទាំងនេះមិនដាក់កម្រិតលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[1]។ កាលណាមេធាវីការពារក្ដីទទួលបានសម្ភារៈឯកសារដែលស្នើសុំមេធាវីការពារក្ដីនឹងធ្វើសំណើសុំការពិចារណាបន្ថែមទៀតលើបញ្ហាទាំងនេះ។ សំណើនេះត្រូវបានដាក់ជាភាសាអង់គ្លេសសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរជូនតាមក្រោយ ដោយសារការបកប្រែភាសាមិនអាចត្រូវបានបញ្ចប់ទាន់ពេលវេលា[2]។

## I. សាវតារ

### ក. យុត្តាធិការលើបុគ្គលក្នុងរឿងក្ដី ០០១

១. ឌុច មិនបានជំទាស់តវ៉ានឹងយុត្តាធិការរបស់ អ.វ.ត.ក. លើរូបគាត់ក្នុងនាមជាអញ្ញត្រកម្មទេ[3]។ ជំនួសវិញ ក្នុងអំឡុងពេលធ្វើសេចក្ដីថ្លែងការណ៍បញ្ចប់របស់គាត់ មេធាវីជាតិដែលការពារក្ដី ឌុច

[1] ខណៈដែលតុលាការក្នុងប្រព័ន្ធច្បាប់ស៊ីវិលខិតខំប្រឹងប្រែងចាត់ការដូចគ្នាទៅលើរឿងក្ដីដូចគ្នា ការប្រើប្រាស់យុត្តិសាស្ត្រគឺមិនខ្លាំងក្លាដូចនៅក្នុងប្រព័ន្ធខំមិនឡូឡើយ។ ឧទាហរណ៍ នៅប្រទេសបារាំង តុលាការមិនចាំបាច់អនុវត្តតាមទ្រឹស្ដី *គោលការណ៍ច្បាប់ដែលសម្រេចលើវិវាទអនុលោមតាមយុត្តិសាស្ត្រ* (*stare decisis*) ទេ និង មិនជាប់កាតព្វកិច្ចគោរពតាមសេចក្ដីសម្រេចមុនៗឡើយ ហើយក៏មិនចាំបាច់ធ្វើយុត្តិកម្មចំពោះការខកខានមិនបានអនុវត្តតាមសេចក្ដីសម្រេចមុនៗណាមួយរបស់តុលាការដែរ។ "តាមពិត តុលាការកំពូល (Court of Cassations) ដែលជាតុលាការដោះស្រាយបណ្ដឹងសាទុក្ខនាំមុខបារាំង មិនដែលនិយាយអំពីយុត្តិសាស្ត្រតុលាការណាមួយឡើយ នៅក្នុងមតិយោបល់របស់ខ្លួន។ ជាងនេះទៅទៀត តុលាការបារាំងត្រូវបានហាមឃាត់មិនឲ្យថ្លែងអំពីវិធានច្បាប់ ដើម្បីធ្វើយុត្តិកម្មចំពោះសេចក្ដីសម្រេចរបស់ខ្លួន លើកឡើងតែវិធាននោះត្រូវបានចែងរួចហើយនៅក្នុងច្បាប់"។ James Hardisty *ការឆ្លុះបញ្ចាំងទៅលើ* គោលការណ៍ច្បាប់ដែលសម្រេចលើវិវាទអនុលោមតាមយុត្តិសាស្ត្រ (Reflections on Stare Decisis) 55 IND. L.J. 41, 50-51 (ឆ្នាំ ១៩៧៩)។

[2] *សូមមើល* សារអេឡិចត្រូនិចពីលោក គាំ ច័ន្ទមុន្នី ផ្ញើជូនមេធាវីការពារក្ដី "ឆ្លើយតប៖ សំណើសុំការបកប្រែភាសា" ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ដែលចង្អុលបង្ហាញថា ការបកប្រែមិនអាចបញ្ចប់បានទេរហូតដល់ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៥។

[3] អញ្ញត្រកម្មតែមួយគត់ដែលលើកឡើងដោយមេធាវីការពារក្ដី *ឌុច* ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការអនុវត្តឧក្រិដ្ឋកម្មថ្នាក់ជាតិ ដោយសារការផុតអាជ្ញាយុកាលដែលអនុវត្តចំពោះឧក្រិដ្ឋកម្មបែបនេះ។ *សូមមើល រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំ

បានអះអាងថា អ.វ.ត.ក. គ្មានយុត្តាធិការលើ ឌុច ទេ ពីព្រោះគាត់មិនមែនជា *មេដឹកនាំជាន់ខ្ពស់* ហើយក៏មិនមែនជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែរ[4]។

២. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ឌុច បានខកខានមិនបានជំទាស់ឲ្យបានទាន់ពេលវេលាទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. លើរូបគាត់។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃតាមការផ្តើមគំនិតរបស់ខ្លួនថា តើ អ.វ.ត.ក. មានយុត្តាធិការលើរូបគាត់ ឬយ៉ាងណា[5]។ អង្គជំនុំជម្រះបានសម្រេចថា៖ "យុត្តាធិការលើរូបបុគ្គល ត្រូវបានកំណត់ចំពោះ 'មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ' ឬ 'ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិនានា ដែលប្រទេសកម្ពុជាបានទទួលស្គាល់'"[6]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា៖ "កិច្ចព្រមព្រៀង អ.វ.ត.ក. និង ច្បាប់ អ.វ.ត.ក. មិនមានចែងច្បាស់អំពី 'មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ' ឬ 'ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត' នោះទេ"[7]។

៣. ដើម្បីកំណត់អត្ថន័យនៃពាក្យថា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយឆាប់រហ័ស និង សង្ខេបទៅលើអនុសាសន៍របស់ក្រុមអ្នកជំនាញ អ.ស.ប. រួមទាំងពាក្យពេចន៍ពីអគ្គលេខាធិការ អ.ស.ប. និង គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស[8]។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("សាលាក្តី ICTY") និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") ពិនិត្យទាំងទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង កម្រិតនៃការទទួលខុសត្រូវរបស់ជន

---

រឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៩ ឯកសារ E1/3.1 ទំព័រ ៥ ដល់ ៨។

[4] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ E1/80.1 ទំព័រ ៨៤ ដល់ ១០៤។

[5] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ១៤ ដល់ ១៥។

[6] *ដូចខាងលើ* កថាខណ្ឌ ១៧។

[7] *ដូចខាងលើ* កថាខណ្ឌ ១៩។

[8] *ដូចខាងលើ* កថាខណ្ឌ ១៩ ដល់ ២១។

ជាប់ចោទ[9]។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំងនេះដើម្បីសន្និដ្ឋានថា ឌុច "ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ជាលក្ខណៈបុគ្គល ក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩"[10]។ អង្គជំនុំជម្រះបានរកឃើញថា មិនចាំបាច់ពិនិត្យលើបញ្ហាថា តើគាត់ជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះទេ[11]។

៤. ក្នុងបណ្តឹងសាទុក្ខ ភាគីមិនបានជំទាស់តវ៉ាថាតើ ពាក្យនេះជាបញ្ហាយុត្តាធិការ ឬ ជាបញ្ហាឆន្ទានុសិទ្ធិនៃគោលនយោបាយនៃការស៊ើបអង្កេត និង ការចោទប្រកាន់ ឬយ៉ាងណាឡើយ។ ឌុច បានលើកទឡ្ហីករណ៍ត្រឹមតែថា គាត់មិនមែនជា *មេដឹកនាំជាន់ខ្ពស់* ឬ ជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ប៉ុណ្ណោះ[12]។ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព.") និង ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ បានលើកទឡ្ហីករណ៍ថា ការជំទាស់តវ៉ារបស់ ឌុច គឺមិនទាន់ពេលវេលា តែមិនបានជំទាស់ទៅនឹងការសន្មតដែលថា ពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ដាក់កម្រិតលើយុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក. ឡើយ[13]។

៥. អង្គជំនុំជម្រះតុលាការកំពូលបានអញ្ជើញភាគីឲ្យដាក់សារណាផ្ទាល់មាត់លើបញ្ហាថា តើពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនដែលទទួលខុសត្រូវខ្ពស់បំផុត" "គឺជាលក្ខខណ្ឌយុត្តាធិការដែលតម្រូវឲ្យមានការពិនិត្យឡើងវិញរបស់តុលាការ ឬ ជាការណែនាំពីឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេតដែលមិនតម្រូវឲ្យមានការពិនិត្យឡើង

---

[9] *ដូចខាងលើ* កថាខណ្ឌ ២២។

[10] *ដូចខាងលើ* កថាខណ្ឌ ២៥។

[11] *ដូចខាងលើ*។

[12] *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ F14 កថាខណ្ឌ ១ ដល់ ៦៥។

[13] *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសារទុក្ខរបស់សហមេធាវីការពារក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ F14/4។ *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សារណាឆ្លើយតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីការពារ ឌុច ជំទាស់នឹងសាលក្រមដែលបានចេញនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ F14/2។

វិញរបស់តុលាការ ដែរឬទេ"[14]។ នៅឯសវនាការលើបណ្ដឹងសាទុក្ខ មេធាវីការពារក្ដី ឌុច មិនបាន ធ្វើសំណើសុំការពិចារណាជាក់លាក់ណាមួយលើបញ្ហានេះទេ តែបានលើកទឡ្ហីករណ៍ថា អ.វ.ត.ក. គ្មានយុត្តាធិការបុគ្គលលើ ឌុច ទេ។ សហព្រះរាជអាជ្ញាជាតិបានថ្លែងដោយមិនមានការបរិយាយ លំអិតនៅក្នុងចម្លើយតបទៅនឹងសំណួរដោយផ្ទាល់មួយពីចៅក្រម Noguchi ថា៖ "ខ្ញុំគិតថាមិន មែនជាយុត្តាធិការទេ តែជាការមួយដែលយើងពិនិត្យទៅលើសមត្ថកិច្ច ហើយក្នុងការប្រើឆន្ទានុ សិទ្ធិក្នុងការជ្រើសរើសក្នុងការចោទប្រកាន់"[15]។ សហព្រះរាជអាជ្ញាអន្តរជាតិនៅស្ងៀម។ មេធាវី អន្តរជាតិដែលតំណាងក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣ បានលើកទឡ្ហីករណ៍ថា ពាក្យថា *មេដឹក នាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* គឺជា "លក្ខខណ្ឌយុត្តាធិការ"[16]។

៦. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា តើជនណាម្នាក់ត្រូវបានចាត់ទុកជា *មេដឹកនាំជាន់ខ្ពស់* ឬ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ឬយ៉ាងណានោះ មិនមែនជាបញ្ហាយុត្តាធិការដែលត្រូវដោះ ស្រាយតាមផ្លូវតុលាការទេ តែជាបញ្ហាគោលនយោបាយនៃការចោទប្រកាន់ និង ការស៊ើបអង្កេត សម្រាប់ ក.ស.ព. និង ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស.")[17]។ អង្គជំនុំជម្រះ បានសម្រេចថា សេចក្ដីសម្រេចចោទប្រកាន់ ឬ ស៊ើបអង្កេត គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញតាម រយៈបណ្ដឹងសាទុក្ខលើការបំពានឆន្ទានុសិទ្ធិ[18]។

៧. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អនុលោមតាមអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់ សន្ធិសញ្ញា ("អនុសញ្ញា VCLT")[19] អង្គជំនុំជម្រះចាំបាច់ត្រូវពិចារណាលើអត្ថន័យធម្មតានៃពាក្យ

---

[14] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ដីកាកំណត់កាលបរិច្ឆេទសវនាការ បណ្ដឹងសាទុក្ខ ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១១ ឯកសារ F20 ទំព័រ ៣។

[15] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំ ជម្រះក្ដីលើបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១១ ឯកសារ F1/2.1 ទំព័រ ៩១។

[16] *ដូចខាងលើ* ទំព័រ ១០៥។

[17] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីការឿងក្ដី ០០១") កថាខណ្ឌ ៦២ ដល់ ៧៩។

[18] *ដូចខាងលើ* កថាខណ្ឌ ៨០។ ដំបូង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាតើ ឃ្លា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជា ប្រជាធិបតេយ្យ និង បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើមនុស្សមួយ ឬ ពីរប្រភេទ ដោយសម្រេចថា ឃ្លានេះសំដៅ លើមនុស្សពីរប្រភេទគឺ៖ "មេដឹកនាំជាន់ខ្ពស់នៃខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត" និង "បុគ្គលដែល មិនមែនជាសមាជិកជាន់ខ្ពស់នៃខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ"។ *ដូចខាងលើ* កថាខណ្ឌ ៤៤ ដល់ ៥៧។

[19] អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៦៩ 1155 U.N.T.S. 331។

ពេចន៍នៃកិច្ចព្រមព្រៀង[20] ដោយគិតពីកម្មវត្ថុ គោលបំណង និង បរិបទ ហើយអាចងាកទៅរកន័យបន្ថែមនៃការបកស្រាយ រួមទាំងការងាររៀបរៀងសន្ធិសញ្ញា នៅពេលដែលសន្ធិសញ្ញានោះត្រូវបានជឿថា មានអត្ថន័យមិនច្បាស់លាស់។ អង្គជំនុំជម្រះតុលាការកំពូលក៏បានពិចារណាផងដែរថា ខ្លួនអាច "ស្វែងរកបទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលមានបទប្បញ្ញត្តិប្រហាក់ប្រហែលនៅក្នុងយុត្តាធិការផ្សេងៗទៀត" អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង[21]។

៨. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា នៅក្នុងបរិបទពាក្យថា "យុត្តាធិការលើបុគ្គល" នៅក្នុងមាត្រា ២(១) នៃកិច្ចព្រមព្រៀង បង្ហាញថា ពាក្យនេះដើរតួនាទីជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់នៃយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង[22]។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា ខ្លួននឹងពិចារណាថា តើការបកស្រាយនេះស្របទៅនឹងកម្មវត្ថុ និង គោលបំណងរបស់កិច្ចព្រមព្រៀងឬយ៉ាងណា និង ថា តើវានឹងនាំឲ្យមានលទ្ធផលដែលមិនសមហេតុផលឬយ៉ាងណា[23]។

៩. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើបុគ្គលបីប្រភេទ៖ "កម្មាភិបាលខ្មែរក្រហម" "អ្នកទទួលខុសត្រូវខ្ពស់បំផុត" និង "មេដឹកនាំជាន់ខ្ពស់"។ ទាក់ទងនឹងប្រភេទ *កម្មាភិបាលខ្មែរក្រហម* អង្គជំនុំជម្រះបានសម្រេចថា នេះជាការដាក់កម្រិតផ្នែកយុត្តាធិការ ពីព្រោះអង្គជំនុំជម្រះសាលាដំបូង គឺជាអ្នកមានសមត្ថកិច្ចត្រឹមត្រូវជាងគេ នៅក្នុងការសម្រេចលើបញ្ហាអង្គហេតុនេះ[24]។ ទោះជាយ៉ាងនេះក្តី ទាក់ទងនឹងពាក្យ *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* អង្គជំនុំជម្រះបានសម្រេចថា វានឹងនាំឲ្យមានលទ្ធផលមិនសមហេតុផល ប្រសិនបើពាក្យទាំងនេះត្រូវបានបកស្រាយជាការដាក់កម្រិតផ្នែកយុត្តាធិការ ដោយពិចារណាទៅលើកម្មវត្ថុ និង គោលបំណងនៃកិច្ចព្រមព្រៀង។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា៖

ក. "ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និង ធ្វើការកំណត់ចំណាត់ថ្នាក់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់

---

[20] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។

[21] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៥៩។

[22] វាមិនច្បាស់ថា មូលហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលសំដៅជាក់លាក់លើយុត្តាធិការរបស់ *អង្គជំនុំជម្រះសាលាដំបូង* នៅទីនេះ ជាជាងយុត្តាធិការរបស់ អ.វ.ត.ក. ទាំងមូល។

[23] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦០។

[24] *ដូចខាងលើ* កថាខណ្ឌ ៦១។

កម្ពុជាភិបាលខ្មែរក្រហមទាំងអស់ឡើយ”[25]។

ខ. សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[26] ដែលចែងថា តួនាទី ឬ ឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬ ជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។ ការធ្វើបែបនេះ គឺមានន័យស្មើនឹងការបង្កើតឲ្យមានមធ្យោបាយការពារដោយប្រយោល ដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយទៅនឹងគោលបំណងនៃមាត្រា ២៩[27]។ និង

គ. ការកំណត់ថា តើជនណាម្នាក់ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតឬយ៉ាងណានោះ តម្រូវឲ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន[28]។

១០. អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា សមត្ថកិច្ចដែលផ្តល់ដល់សហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា ជាសូចនាករ “ចម្បង” ក្នុងចំណោមសូចនាករ “ជាច្រើន” ដែលថាពាក្យថា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* គួរត្រូវបានបកស្រាយថា ជាគោលនយោបាយនៃការស៊ើបអង្កេត និង ការចោទប្រកាន់ ដែលមិនអាចយកវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានឡើយ[29]។ បើនិយាយពីប្រវត្តិនៃការព្រាងកិច្ចព្រមព្រៀងវិញ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ក្រុមអ្នកជំនាញ អ.ស.ប. បានផ្តល់យោបល់ឲ្យបកស្រាយពាក្យ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ថាជាគោលនយោបាយណែនាំ[30]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានងាកទៅរកយុត្តិសាស្ត្រអន្តរជាតិផងដែរ ដោយកត់សម្គាល់ថា ការប្រៀបធៀបរវាង អ.វ.ត.ក. ជាមួយ សាលាក្តី ICTY និង សាលាក្តីអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (“សាលាក្តី ICTR”)

---

[25] *ដូចខាងលើ* កថាខណ្ឌ ៦២។

[26] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.”)។

[27] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២។

[28] *ដូចខាងលើ*។

[29] *ដូចខាងលើ* កថាខណ្ឌ ៦៣ ដល់ ៦៤។ មាត្រា ៥(៣) និង ៦(៣) នៃកិច្ចព្រមព្រៀង ផ្តល់សិទ្ធិអំណាចដល់សហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា ក្នុងការសម្រេចថា តើការស៊ើបអង្កេត ឬ ការចោទប្រកាន់ជាក់លាក់ ស្ថិតនៅក្នុងវិសាលភាពនៃពាក្យថា “ជនដែលទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណា។

[30] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦៦ ដល់ ៦៨។

បង្ហាញថា ពាក្យនេះគឺជាគោលនយោបាយណែនាំ ជាជាងការដាក់កម្រិតផ្នែកយុត្តាធិការ[31]។ អង្គជំនុំជម្រះបានសម្រេចថា យន្តការបញ្ជូនរឿងក្តីរបស់សាលាក្តី ICTY បង្ហាញថា ពាក្យនេះមិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការទេ តែជាការឆ្លុះបញ្ចាំងនូវគោលនយោបាយនៃការចោទប្រកាន់[32] និង បានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Brima និង អ្នកផ្សេងទៀត* នៃតុលាការ SCSL បានសម្រេចថា ពាក្យថា "ការទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខន្តិកៈនៃតុលាការ SCSL មិនមែនជាបញ្ហាយុត្តាធិការទេ[33]។

១១. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា អង្គជំនុំជម្រះមិនចាត់ទុកពាក្យថា *មេដឹកនាំជាន់ខ្ពស់* ដើរតួនាទីជាការដាក់កម្រិតផ្នែកយុត្តាធិការឡើយ ដោយសារពាក្យនេះ គឺ "មានភាពបត់បែនគ្រប់គ្រាន់" ដែលវាមិនអាចត្រូវបានដាក់កម្រិតឲ្យនៅត្រឹមតែសមាជិកគណៈកម្មាធិការមជ្ឈិម ឬ គណៈកម្មាធិការអចិន្ត្រៃយ៍នោះទេ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ការពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាកម្ពុជាបញ្ជាក់ថា និយមន័យនៃពាក្យនេះមិនត្រូវបានកំណត់ឡើយ[34]។

### ខ. យុត្តាធិការលើបុគ្គលក្នុងរឿងក្តី ០០៣

១២. សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង ចៅក្រម Siegfried Blunk បានដាក់សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរក្នុងរឿងក្តី ០០៣ ដោយមិនបានចោទប្រកាន់ជនសង្ស័យណាម្នាក់ឡើយ[35]។ នៅក្នុងកិច្ចសម្ភាសន៍មួយ សហចៅក្រមស៊ើបអង្កេត Blunk បានពន្យល់ថា៖ "សម្រាប់រឿងក្តី ០០៣ និង ០០៤ យើងបានធ្វើការវិភាគស៊ីជម្រៅទៅលើប្រភព និង អត្ថន័យនៃពាក្យ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" និង បានបង្កើតលក្ខណៈវិនិច្ឆ័យមួយឈុត ដែលផ្អែកលើច្បាប់ អ.វ.ត.ក. និង យុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិ ជាពិសេស យុត្តិសាស្ត្រនៃតុលាការសម្រាប់

---

[31] នៅឯសាលាក្តី ICTY វិធាន ២៨(ក) តម្រូវឲ្យមានការិយាល័យមួយសម្រាប់ពិនិត្យថា តើដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់ដែលត្រូវបានសង្ស័យថាជាជនដែលទទួលខុសត្រូវខ្ពស់បំផុតឬយ៉ាងណា។ ប្រសិនបើការិយាល័យនេះរកឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានផ្តោតលើចំណុចនេះទេ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងមិនត្រូវបានបញ្ជាក់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការសង្កេតថា សាលាក្តី ICTR មានវិធានស្រដៀងគ្នានេះ បទប្បញ្ញត្តិទាំងនេះមិនដាក់កម្រិតលើយុត្តាធិការរបស់អង្គជំនុំជម្រះឡើយ ហើយជនជាប់ចោទមិនអាចជំទាស់ថា តុលាការគ្មានយុត្តាធិការ ដោយផ្អែកលើបទប្បញ្ញត្តិទាំងនេះឡើយ។ *ដូចខាងលើ* កថាខណ្ឌ ៦៩។

[32] *ដូចខាងលើ* កថាខណ្ឌ ៧១។

[33] *ដូចខាងលើ* កថាខណ្ឌ ៧២ ដល់ ៧៣។

[34] *ដូចខាងលើ* កថាខណ្ឌ ៧៥ ដល់ ៧៦។

[35] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។

ប្រទេសសៀវ៉ាឡេអូន ពីព្រោះយុត្តាធិការរបស់តុលាការនេះត្រូវបានដាក់កម្រិតស្រដៀងគ្នានឹងបុគ្គលដែល "មានការទទួលខុសត្រូវខ្ពស់បំផុត""[36]។

១៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ("ស.ច.ស.អ.ប.") បានបើករឿងក្តីជាថ្មីជាឯកតោភាគី[37]។ ពីរថ្ងៃមុនពេលលាលែងចេញពីមុខតំណែង គាត់បានចេញដីកាសម្រេចលើយុត្តាធិការលើបុគ្គល និង គោលនយោបាយស្តីពីការស៊ើបអង្កេត "ដើម្បីធានាដំណើរការតាមផ្លូវច្បាប់ត្រឹមត្រូវ និង មានតម្លាភាព"[38]។ ស.ច.ស.អ.ប. បានសម្រេចថា បញ្ហាថាតើបុគ្គលណាម្នាក់ជា *មេដឹកនាំជាន់ខ្ពស់* ឬ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* គឺជាបញ្ហានៃគោលនយោបាយនៃការស៊ើបអង្កេតជាជាងយុត្តាធិការ[39] និង បានបង្កើតលក្ខណៈវិនិច្ឆ័យដែលផ្អែកលើយុត្តិសាស្ត្ររបស់សាលាក្តី ICTY ដើម្បីសម្រេចថា តើបុគ្គលណាម្នាក់អាចត្រូវបានចាត់ទុកថាជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ឬយ៉ាងណា[40]។ បន្ទាប់មក គាត់បានសន្និដ្ឋានថា លោក មាស មុត គឺជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ចំពោះបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[41]។ [redacted][42]។

១៤. នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានស្នើ ក.ស.ច.ស. ឱ្យផ្តល់លក្ខណៈវិនិច្ឆ័យរបស់ខ្លួន សម្រាប់កំណត់ថា តើបុគ្គលណាម្នាក់ជា *មេដឹកនាំជាន់ខ្ពស់* ឬ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត*[43]។ នៅថ្ងៃដដែលនោះ មេធាវីការពារក្តីក៏បានស្នើសុំផងដែរឱ្យ ក.ស.ច.ស. បង្គាប់

---

[36] Thomas Miller *ចៅក្រមនៅសាលាក្តីខ្មែរក្រហមនិយាយអំពីបញ្ហាចម្រូងចម្រាស់នៅតុលាការ* (KRT Judge Talks Court Controversies) កាសែតភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១។

[37] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D28។

[38] ដីកាសម្រេចលើយុត្តាធិការលើបុគ្គល និង គោលនយោបាយនៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី ២ ខែឧសភា ឆ្នាំ ២០១២ ឯកសារ D48 ("ដីកាសម្រេចលើយុត្តាធិការលើបុគ្គល") កថាខណ្ឌ ១។

[39] *ដូចខាងលើ* កថាខណ្ឌ ១១ ដល់ ១៣។

[40] *ដូចខាងលើ* កថាខណ្ឌ ១៥ ដល់ ១៦។

[41] *ដូចខាងលើ* កថាខណ្ឌ ២៧។

[42] *សូមមើល* [redacted]។

[43] សំណើរបស់លោក មាស មុត សុំលក្ខណៈវិនិច្ឆ័យរបស់ ក.ស.ច.ស. ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង បុគ្គលដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.10។

ក.ស.ព. ឲ្យផ្ដល់នូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួន សម្រាប់កំណត់ថា តើជនសង្ស័យសក្ដិសមនឹងអត្ថន័យនៃពាក្យទាំងនេះ ឬយ៉ាងណា[44]។ មកទល់នឹងពេលនេះ គ្មានលក្ខណៈវិនិច្ឆ័យណាមួយត្រូវបានផ្ដល់ ដើម្បីជាការឆ្លើយតបទៅនឹងសំណើទាំងនេះទេ។

## II. ភាពអាចទទួលយកបាន

១៥. សំណើនេះស្នើសុំសម្ភារៈឯកសារដែលចាំបាច់ ដើម្បីបញ្ជាក់ថា ពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ដើរតួនាទីជាការដាក់កម្រិតផ្នែកយុត្ដាធិការទៅលើ អ.វ.ត.ក. និង ដើម្បីបញ្ជាក់អត្ថន័យនៃពាក្យទាំងនេះ។ សម្ភារៈឯកសារនេះ គឺចាំបាច់ សម្រាប់ឲ្យមេធាវីការពារក្ដីអាចបង្ហាញនូវទឡ្ហីករណ៍ពេញលេញ ទាក់ទងនឹងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលថា ពាក្យ *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* មិនមែនជាការដាក់កម្រិតផ្នែកយុត្ដាធិការ និង អាចបង្ហាញនូវការបកស្រាយត្រឹមត្រូវនៃពាក្យទាំងនេះទៀតផង។

១៦. សម្ភារៈឯកសារដែលបានស្នើ អាចត្រូវបានស្នើសុំដោយ ក.ស.ច.ស. អនុលោមតាមវិធាន ៥៥(៥)(គ)។ សំណើនេះអាចទទួលយកបានតាមវិធាន ៥៥(១០) និង ៥៨(៦) និង បំពេញលក្ខខណ្ឌតម្រូវនៃវិធានទាំងនេះ៖[45] សំណើនេះកំណត់ច្បាស់លាស់នូវកិច្ចស៊ើបសួរដែលត្រូវបំពេញ (ការទទួលយកសម្ភារៈឯកសារពី អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាដើម្បីបង្កើត អ.វ.ត.ក. និង ការព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និង ការដាក់សម្ភារៈឯកសារនេះទៅក្នុងសំណុំរឿង)។ វាទាក់ទង *ជាបឋម* (prima facie) ទៅនឹងវិសាលភាពនៃការស៊ើបសួរ ដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖ វាទាក់ទងនឹងការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចំពោះតួនាទីរបស់

[44] សំណើរបស់ មាស មុត សុំ ក.ស.ច.ស. បង្គាប់ឲ្យ ក.ស.ព. ផ្ដល់ឲ្យមេធាវីការពារក្ដីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួនទាក់ទង "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.11។

[45] *សូមមើល រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ដឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៤៧ ដល់ ៤៨។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្ដុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៤។

មាស មុត និង ថាតើគាត់អាចត្រូវបានចាត់ទុកថាជា *មេដឹកនាំជាន់ខ្ពស់* ឬ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ឬយ៉ាងណា។ វាជួយក្នុងការស្វែងរកការពិត និង មានប្រយោជន៍សម្រាប់ដំណើរការស៊ើបអង្កេត[46]។

## III. សំណើ

### ក. អង្គជំនុំជម្រះតុលាការកំពូលមានកំហុសនៅក្នុងការចាត់ទុកពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ជាបញ្ហាអន្តរាគមន៍សិទ្ធិនៃការចោទប្រកាន់ និង ការស៊ើបអង្កេត ជាជាងការដាក់កម្រិតយុត្តាធិការ

១៧. យោងតាមអនុសញ្ញា VCLT[47] និង បទប្បញ្ញត្តិទូទៅស្តីពីការបកស្រាយច្បាប់[48] ការពិចារណាលើពាក្យពេចន៍សាមញ្ញនៃបទប្បញ្ញត្តិមួយ គឺជាចំណុចចាប់ផ្តើមក្នុងការកំណត់អំពីអត្ថន័យរបស់វា។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពាក្យពេចន៍សាមញ្ញនៃកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បង្ហាញថា ពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ដាក់កម្រិតលើយុត្តាធិការរបស់ អ.វ.ត.ក.[49]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូល

---

[46] ស្ថានភាពនេះគឺខុសពីស្ថានភាពនៃរឿងក្តី ០០២ ដែលក្រុមមេធាវីការពារក្តីបានស្នើសុំឲ្យ ក.ស.ច.ស. ពិនិត្យឃ្លាំងផ្ទុកឯកសាររួម (“SMD”) ទាំងមូល និង ដាក់ឯកសារដោះបន្ទុកពីឃ្លាំងផ្ទុកឯកសារនេះទៅក្នុងសំណុំរឿង។ នៅពេលនោះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា សំណើរបស់ក្រុមមេធាវីការពារក្តីមិនមានភាពជាក់លាក់គ្រប់គ្រាន់ ដោយសារក្រុមមេធាវីការពារក្តីបានចូលឃ្លាំងផ្ទុកឯកសាររួម និង អាចធ្វើឲ្យសំណើរបស់ខ្លួនមានភាពជាក់លាក់បាន។ *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៤ ដល់ ៤៦។

[47] មាត្រា ៣១។

[48] ច្បាប់កម្ពុជាមិនបានបញ្ញត្តិអំពីវិធានដែលកំណត់អំពីការបកស្រាយច្បាប់ឡើយ។ ដោយសារតែប្រព័ន្ធច្បាប់កម្ពុជាមានមូលដ្ឋានលើប្រព័ន្ធបារាំង វិធីសាស្ត្របារាំងក្នុងការបកស្រាយច្បាប់ អាចយកមកធ្វើជាជំនួយបាន។ តាមវិធីសាស្ត្រនេះ ប្រសិនបើអត្ថបទច្បាប់មានលក្ខណៈមិនច្បាស់លាស់ តុលាការនឹងព្យាយាមស្វែងយល់អំពីគោលបំណងរបស់អង្គនីតិបញ្ញត្តិ រួមទាំងងាកទៅពិនិត្យមើលការងាររៀបចំ (traveaux préparatoires) ដើម្បីរកឲ្យឃើញនូវគោលគំនិតរបស់អង្គនីតិបញ្ញត្តិនោះ។ *សូមមើល* Claire M. Germain *វិធីសាស្ត្រឈានទៅរកការបកស្រាយច្បាប់ និង ប្រវត្តិនីតិប្បញ្ញត្តិក្នុងប្រទេសបារាំង* (Approaches to Statutory Interpretation and Legislative History in France) 13 DUKE J. COMP. & INT’L L. 195, 201-02 (ឆ្នាំ ២០០៣)។

[49] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦០។

បានសន្និដ្ឋានដោយភ័ន្តច្រឡំថា ការបកស្រាយពាក្យពេចន៍សាមញ្ញនេះ នឹងនាំឲ្យមានលទ្ធផលដែលមិនសមហេតុផល[50]។

១៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍ទាំងនេះមិនអាចជាការដាក់កម្រិតផ្នែកយុត្តាធិការទេ ពីព្រោះសញ្ញាណនៃការទទួលខុសត្រូវព្រហ្មទណ្ឌប្រៀបធៀប គឺមិនស៊ីសង្វាក់នឹងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឡើយ[51]។ ទោះបីជាយ៉ាងនេះក្តី មាត្រា ២៩ថ្មី គ្រាន់តែអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ប៉ុណ្ណោះ។ គឺជន *ទាំងនោះ* ដែលមុខតំណែង និង ឋានៈរបស់ពួកគេ មិនអាចជួយពួកគេឲ្យរួចផុតពីការទទួលខុសត្រូវ ឬ បន្ធូរបន្ថយទណ្ឌកម្មឡើយ។ មាត្រានេះ មិនបាននិយាយអ្វីទាំងអស់អំពីជនផ្សេងៗទៀតដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។ យោងតាមមាត្រា ២៩ថ្មី បុគ្គលម្នាក់ដែលត្រូវបានរកឃើញថាស្ថិតនៅក្នុងប្រភេទនៃ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ប៉ុន្តែមានឋានៈទាប មិនអាចផ្អែកទៅលើឋានៈទាបរបស់គាត់ដើម្បីបន្ធូរបន្ថយទណ្ឌកម្មរបស់គាត់ឡើយ។ បុគ្គលបែបនេះ មិនអាចផ្អែកទៅលើមធ្យោបាយការពារ ដោយមូលហេតុបញ្ជារបស់ថ្នាក់លើឡើយ។ ស្រដៀងគ្នានេះដែរ លក្ខន្តិកៈរបស់សាលាក្តី ICTY ចែងថា៖ “ប្រការដែលថា ជនជាប់ចោទបានប្រព្រឹត្តអំពើ ទៅតាមបញ្ជារបស់រដ្ឋាភិបាល ឬ ថ្នាក់លើ មិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ...”[52]។ ប៉ុន្តែ សាលាក្តី ICTY នៅតែពិចារណាថា តើបុគ្គលម្នាក់បានប្រព្រឹត្តអំពើទៅតាមបញ្ជា ឬយ៉ាងណា នៅពេលធ្វើការសម្រេចថា តើបុគ្គលនោះបំពេញ ឬ មិនបំពេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់បញ្ជូនរឿងក្តីទៅតុលាការជាតិ តាមវិធានសាលាក្តី ICTY ១១*ស្ទួន* [53]។ គ្មានភាពមិនស៊ីសង្វាក់គ្នារវាងការសម្រេចថា តើបុគ្គលម្នាក់ស្ថិត ឬ មិនស្ថិតនៅក្នុងយុត្តាធិការរបស់

---

[50] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២។ “ភាពមិនសមហេតុផល” ត្រូវបានឲ្យនិយមន័យថាជា “ភាព ឬ លក្ខណៈដែលមិនសមហេតុផលទាល់តែសោះ ជាពិសេស ការបកស្រាយដែលនឹងនាំឲ្យមានលទ្ធផលមិនសមហេតុផល ជាពិសេសការបកស្រាយមួយដែលភាគី ឬ (ជាពិសេសសម្រាប់ច្បាប់) អ្នកព្រាងមិនអាចមានបំណង និង ប្រហែលជាមិនដែលបានគិតដូច្នេះ” វចនានុក្រម BLACK'S LAW 10 (បោះពុម្ពលើកទី ៩ ឆ្នាំ ២០០៩)។

[51] អង្គជំនុំជម្រះតុលាការកំពូលផ្តល់សំអាងហេតុថា ការធ្វើបែបនេះគឺមានន័យស្មើនឹងការបង្កើតឲ្យមានមធ្យោបាយការពារដោយប្រយោល ដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយនឹងគោលបំណងនៃមាត្រា ២៩។ *សូមមើល* សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២។

[52] មាត្រា ៧(៤) នៃលក្ខន្តិកៈសាលាក្តី ICTY។

[53] *សូមមើល រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង *Lukić & Lukić* សំណុំរឿងលេខ IT-98-32/1-AR11 *bis*.1 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ស្តីពីការបញ្ជូនរឿងក្តី ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២១-២២។

អ.វ.ត.ក. និង ការអនុវត្តមាត្រា ២៩ថ្មី ឡើយ។ គ្មានលទ្ធផលដែលមិនសមហេតុផល កើតមានឡើងឡើយ។

១៩. ផ្ទុយទៅវិញ លទ្ធផលដែលមិនសមហេតុផលនឹងកើតមានឡើង ប្រសិនបើពាក្យពេចន៍ទាំងនេះត្រូវបានចាត់ទុកថាគ្រាន់តែជាគោលការណ៍ណែនាំ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនៃការចោទប្រកាន់ និង ការស៊ើបអង្កេតប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ពុំមាន *វិធីសាស្ត្រជាសត្យានុម័ត* សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និង ធ្វើការកំណត់ចំណាត់ថ្នាក់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ របស់កម្មាភិបាលខ្មែរក្រហមទាំងអស់បានឡើយ"[54]។ ប្រសិនបើពិតជាដូច្នេះមែននោះ ប្រភេទបុគ្គលបែបនេះ មិនគួរត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក. ឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប. បានចង្អុលបង្ហាញថា៖ "ប្រសិនបើ ... នីតិវិធីព្រហ្មទណ្ឌពិសេស ឬ តុលាការ ឬ សាលាក្តីដែលបង្កើតឡើងជាពិសេស អនុវត្តនៅក្នុងការកំណត់អំពីប្រភេទមួយចំនួននៃរឿងក្តីនោះ *ត្រូវតែមានការផ្តល់នូវមូលដ្ឋានជាសត្យានុម័ត និង សមហេតុផលដើម្បីធ្វើយុត្តិកម្មចំពោះភាពខុសគ្នានេះ*"[55]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេច[56] ប្រសិនបើ "ឆន្ទានុសិទ្ធិយ៉ាងច្រើន" ជាប់ពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចថា តើបុគ្គលម្នាក់នឹងត្រូវបានចោទប្រកាន់ ឬ ស៊ើបអង្កេតនៅ អ.វ.ត.ក. ឬយ៉ាងណានោះ និង "ពុំមាន *វិធីសាស្ត្រជាសត្យានុម័ត*" សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចបែបនេះ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ[57] ត្រូវបានរំលោភ។ រឿងក្តីស្រដៀងគ្នា មិនអាចដោះស្រាយតាម

---

[54] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២ (សេចក្តីបញ្ជាក់បន្ថែម)។

[55] គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/GC/32 សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និង សាលាក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៤ (សេចក្តីបញ្ជាក់បន្ថែម)។

[56] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២។

[57] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលបានកែប្រែដោយក្រមចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើប្រាស់វិសោធនកម្មលើមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាផ្សេងទៀតចាប់ពីជំពូកទី ៨ រហូតដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩។ មាត្រា ៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ២១៧A (III) ឯកសារ អ.ស.ប. A/810 ត្រង់ចំណុច ៧១ 71 (ឆ្នាំ ១៩៤៨)។ មាត្រា ១៤(១) មាត្រា ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ត្រូវបានអនុម័ត និង បើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក តាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ២២០០ A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ស្របតាមមាត្រា ៤៩។

វិធីស្រដៀងគ្នាឡើយ។ គ្មានវិធីសាស្ត្រជាសត្យានុម័តក្នុងការកំណត់ថាតើនរណាអាចត្រូវបានចោទប្រកាន់នោះឡើយ សេចក្ដីសម្រេចធ្វើការចោទប្រកាន់នឹងធ្វើឡើងតាមតែអំពើចិត្ត និង នាំឲ្យមានការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយ។ ការទុកបញ្ហាថា តើបុគ្គលម្នាក់ជា *មេដឹកនាំជាន់ខ្ពស់ ឬ ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ថាជាគោលនយោបាយនៃការស៊ើបអង្កេត នឹងនាំឲ្យមានការបកស្រាយមិនសមហេតុផលទៅលើកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

២០. ប្រវត្តិនៃការចរចាបង្ហាញថា អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជាមានបំណងប្រើប្រាស់ពាក្យពេចន៍នេះដើម្បីដាក់កម្រិតលើយុត្តាធិការរបស់ អ.វ.ត.ក. ដូចដែលមានបង្ហាញជូននៅក្នុងសម្ភារៈឯកសារដែលបានស្នើសុំ។ ដោយសារតែពាក្យពេចន៍នៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. គឺច្បាស់លាស់ដែលថា ពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដើរតួនាទីជាការដាក់កម្រិតយុត្តាធិការទៅលើ អ.វ.ត.ក. ហើយការបកស្រាយបែបនេះមិននាំឲ្យមានលទ្ធផលមិនច្បាស់លាស់ ស្រពិចស្រពិល មិនសមស្រប ឬ មិនសមហេតុផលនោះ វាមិនចាំបាច់ត្រូវពិនិត្យមើលប្រវត្តិនៃការចរចាឡើយ អនុលោមតាមអនុសញ្ញា VCLT ហើយតាមពិតប្រការនេះមិនត្រូវបានអនុញ្ញាតឡើយ។ ទោះបីជាយ៉ាងនេះក្ដី ដោយសារតែអង្គជំនុំជម្រះតុលាការកំពូល *ពិតជាបាន* ពិនិត្យមើលប្រវត្តិនៃការចរចានោះ អង្គជំនុំជម្រះគួរតែបានពិនិត្យមើលប្រវត្តិពាក់ព័ន្ធទាំងអស់ ជាជាងផ្ដោតទៅលើរបាយការណ៍របស់ក្រុមអ្នកជំនាញ អ.ស.ប.[58]។ ឯកសារ *តែមួយគត់* នៃប្រវត្តិរៀបចំសេចក្ដីព្រាងដែលអាចរកមើលបាន ដែលបង្ហាញនូវការបកស្រាយផ្ទុយនោះ គឺរបាយការណ៍របស់ក្រុមអ្នកជំនាញ អ.ស.ប. ដែលជាឯកសារមួយក្នុងចំណោមឯកសារមិនច្រើនស្ដីពីប្រវត្តិនៃការចរចា ដែលអង្គជំនុំជម្រះតុលាការកំពូលយកមកពិចារណា[59]។

---

[58] ឧទាហរណ៍ អគ្គលេខាធិការរង អ.ស.ប. លោក Hans Corell បានថ្លែងកាលពីខែមីនា ឆ្នាំ ២00៣ ថា នរណាដែលត្រូវស៊ើបអង្កេត និង ចោទប្រកាន់នោះ "គឺជាការសម្រេចដោយឯករាជ្យរបស់សហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា។ *ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងមានការចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការ<u>តែ</u>ទៅលើមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម...*"។ សេចក្ដីថ្លែងការណ៍របស់អគ្គលេខាធិការរង លោក Hans Corell ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២00៣ (សេចក្ដីបញ្ជាក់បន្ថែមជាអក្សរទ្រេត បញ្ជាក់ដោយមានគូសបន្ទាត់ពីក្រោមដូចឯកសារដើម)។ ប្រការនេះបង្ហាញឲ្យឃើញថា អ.ស.ប. បានប្រមើលថា នៅក្នុងយុត្តាធិការបុគ្គលដែលបានកំណត់របស់ អ.វ.ត.ក. សហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេត នឹងអាចអនុវត្តឆន្ទានុសិទ្ធិរបស់ពួកគាត់ក្នុងការជ្រើសរើសនរណាដែលត្រូវចោទប្រកាន់ និង ស៊ើបអង្កេត។

[59] អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើប្រភពខាងក្រោមនេះ៖ ក. លិខិតចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៧ ពីនាយករដ្ឋមន្ត្រីទីមួយ និង ទីពីរនៃរាជរដ្ឋាភិបាលកម្ពុជាជូនចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំជំនួយពី អ.ស.ប. ដើម្បីនាំយកមកកាត់សេចក្ដីនូវជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

ក្រុមអ្នកជំនាញ អ.ស.ប. បានផ្តល់អនុសាសន៍ឲ្យសាលាក្តីអន្តរជាតិយកគំរូតាមសាលាក្តី ICTY និង សាលាក្តី ICTR។ សាលាក្តី ICTY និង សាលាក្តី ICTR មានយុត្តាធិការលើ *គ្រប់* បុគ្គលទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួន[60]។ ដើម្បីធានាថា មនុស្សរាប់រយ ឬ រាប់ពាន់នាក់ មិនត្រូវបានចោទប្រកាន់នៅឯសាលាក្តីខ្មែរក្រហមនោះ ក្រុមអ្នកជំនាញ អ.ស.ប. បានស្នើឡើងថា ព្រះរាជអាជ្ញាត្រូវមានឆន្ទានុសិទ្ធិក្នុងការដាក់កម្រិតលើការចោទប្រកាន់។ ដោយសារតែគំរូសាលាក្តី ICTY/ICTR *មិនមែន* ជាគំរូដែលទីបំផុតត្រូវបានជ្រើសរើសនៅក្នុងការបង្កើត អ.វ.ត.ក. នោះ[61] អនុសាសន៍របស់ក្រុមអ្នកជំនាញ អ.ស.ប. ស្តីពីឆន្ទានុសិទ្ធិនៃការចោទប្រកាន់ គឺមិនពាក់ព័ន្ធ។ គ្មានភស្តុតាងបង្ហាញថា ភាគីណាមួយនៃកិច្ចចរចានោះ ធ្លាប់បានទទួលយកអនុសាសន៍នេះឡើយ[62]។

២១. នៅឯតុលាការ SCSL អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានសម្រេចថា ឃ្លា "បុគ្គលទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុត" គឺជាគោលការណ៍ណែនាំនៃការចោទប្រកាន់ ជាជាងការដាក់កម្រិតផ្នែកយុត្តាធិការ។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់សេចក្តីសម្រេចនេះ ប៉ុន្តែមិនបានថ្លែងថា តើសេចក្តីសម្រេចនេះជាប់ទាក់ទងទៅនឹងការសម្រេចរបស់ខ្លួនផ្ទាល់ ឬយ៉ាងណាឡើយ[63]។ វាបង្ហាញឲ្យឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាលើ

---

ជាតិ ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ (សាលដីការឿងក្តី ០០១ ជើងទំព័រ ៩៩) **ខ.** សេចក្តីសង្ខេបរបស់អគ្គលេខាធិការ អ.ស.ប. អំពីសំណើនេះ (*ដូចខាងលើ* ជើងទំព័រ ១០០) **គ.** សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប. ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៩៧ (*ដូចខាងលើ* ជើងទំព័រ ១០១, ១០៨) **ឃ.** របាយការណ៍របស់ក្រុមអ្នកជំនាញ (*ដូចខាងលើ* ជើងទំព័រ ១០២-១០៤, ១០៧-១០៨, ១២៨) **ង.** *សម័យប្រជុំលើកទីមួយនៃនីតិកាលទីបីរបស់រដ្ឋសភាជាតិកម្ពុជា* ថ្ងៃទី ៤-៥ ខែតុលា ឆ្នាំ ២០០៤ "ការពិភាក្សា និង ការអនុម័តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា និង ការពិភាក្សា និង ការអនុម័តវិសោធនកម្មលើច្បាប់ស្តីពីការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម" (*ដូចខាងលើ* ជើងទំព័រ ១០៥-១០៦, ១៤២) និង **ច.** អត្ថបទសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះ ទាក់ទងនឹងកិច្ចចរចា រួមទាំងអត្ថបទដែលសរសេរដោយលោក Heder ផងដែរ (*ដូចខាងលើ* ជើងទំព័រ ១០៩-១១០, ១៤១)។

[60] *សូមមើល* មាត្រា ១ នៃលក្ខន្តិកៈសាលាក្តី ICTY។ មាត្រា ១ នៃលក្ខន្តិកៈសាលាក្តី ICTR។

[61] ជំនួសវិញ តុលាការជាតិនៅក្នុងប្រព័ន្ធតុលាការកម្ពុជាត្រូវបានបង្កើតឡើង។ *សូមមើល* មាត្រា ១ នៃកិច្ចព្រមព្រៀង។

[62] ឧទាហរណ៍ *សូមមើល* លិខិតចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩ ពីនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការ ឯកសារ អ.ស.ប. A/53/851 និង S/1999/230 ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩។ ហោ ណាំហុង អនុស្សរណៈ (Aide-Memoire) ស្តីពីរបាយការណ៍របស់ក្រុមអ្នកជំនាញ អ.ស.ប. សម្រាប់ប្រទេសកម្ពុជា ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៩៩។

[63] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៧២-៧៣។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលបាន ប្រើប្រាស់សំអាងហេតុស្រដៀងគ្នាមែនទែន។ ទោះបីជាយ៉ាងនេះក្តី ការពឹងផ្អែកបែបនេះគឺខុស កន្លែង។ ភាពខុសគ្នាជាច្រើនរវាងតុលាការ SCSL និង អ.វ.ត.ក. តម្រូវឲ្យមានលទ្ធផលខុសគ្នា។

២២. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានចេញ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចំនួនពីរ (រឿងក្តី *Norman* និង រឿងក្តី *Brima និង អ្នកផ្សេង ទៀត*) បានឈានទៅរកការសន្និដ្ឋានខុសគ្នាអំពីបញ្ហាថា តើឃ្លា "បុគ្គលទាំងឡាយដែលមានការ ទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខន្តិកៈតុលាការ SCSL គឺជាការដាក់កម្រិតផ្នែកយុត្តាធិការ ឬ យ៉ាងណា[64]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានផ្តល់នូវ សំអាងហេតុពីរដែលថា ឃ្លានេះមិនមានលក្ខណៈជាយុត្តាធិការឡើយ។

២៣. ទីមួយ មាត្រា ១ នៃលក្ខន្តិកៈតុលាការ SCSL ចែងថា "លើកលែងតែដូចមានចែងនៅក្នុងកថាខណ្ឌ រង (២) តុលាការពិសេសត្រូវមានអំណាចចោទប្រកាន់បុគ្គលទាំងឡាយដែលមានការទទួលខុស ត្រូវខ្ពស់បំផុត..."។ មាត្រា ១៥ ចែងថា "រដ្ឋអាជ្ញាត្រូវទទួលបន្ទុកក្នុងការស៊ើបអង្កេត និង ការ ចោទប្រកាន់បុគ្គលទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុត..."។ អង្គជំនុំជម្រះ តុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានសម្រេចថា ឃ្លានេះមិនមានលក្ខណៈជា យុត្តាធិការ ពីព្រោះមាត្រាទាំងនេះ សំដៅទៅលើសមត្ថកិច្ចរបស់រដ្ឋអាជ្ញា[65]។ ហេតុផលរបស់អង្គ ជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* គឺទំនងជាមូលដ្ឋានសម្រាប់សេចក្តី

---

[64] *រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Norman និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-04-14-PT សេចក្តីសម្រេចលើសំណើ បឋមរបស់មេធាវីការពារក្តី ស្តីពីកង្វះយុត្តាធិការបុគ្គល ដែលដាក់ក្នុងនាមជនជាប់ចោទ Fofana ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៤។ *រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Brima និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-T សាលក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ៦៣៦-៦៥៩។ *សូមមើល* Charles Chernor Jalloh *ការចោទប្រកាន់ជនទាំងឡាយដែលមាន "ការទទួលខុសត្រូវខ្ពស់បំផុត"៖ បទពិសោធន៍របស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន* (Prosecuting Those Bearing "Greatest Responsibility": The Lessons of the Special Court for Sierra Leone) 96 MARQ. L. REV. 863 (ឆ្នាំ ២០១៣) ។ សាស្ត្រាចារ្យ Jalloh បន្ទាប់ពីបានវិភាគលើសេចក្តីសម្រេចពាក់ព័ន្ធនានា និង ប្រវត្តិនៃការព្រាងលក្ខន្តិកៈតុលាការ SCSL យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បាន សម្រេចដោយមិនត្រឹមត្រូវ ហើយថា អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Norman* (ដែលបានសម្រេចថា ឃ្លានោះគឺមានលក្ខ ណៈជាយុត្តាធិការ) មានវិធីសាស្ត្រប្រសើរជាងនេះ។

[65] *រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Brima និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលដីកា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ២៧៧-២៨២។

សន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា មាត្រា ៥(៣)[66] និង មាត្រា ៦(៣)[67] នៃកិច្ចព្រមព្រៀង គឺជាការចង្អុលបង្ហាញ "សំខាន់" ថា ឃ្លានេះគឺជាឆន្ទានុសិទ្ធិ មិនមែនជាយុត្តាធិការឡើយ។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានយល់ឃើញថា វាពិបាកនឹងជឿក្នុងការសន្និដ្ឋាន បន្ទាប់ពីការជំនុំជម្រះក្តីអស់រយៈពេលយ៉ាងយូរ និង ចំណាយអស់ថវិកាយ៉ាងច្រើន ថា តុលាការគ្មានយុត្តាធិការទៅលើជនជាប់ចោទ ប្រសិនបើតុលាការបានសម្រេចដោយគ្មានវិមតិសង្ស័យថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនោះ[68]។ គ្មានហេតុផលណាមួយក្នុងចំណោមហេតុផលទាំងពីរនេះ អាចយកមកអនុវត្តបាននៅ អ.វ.ត.ក. ឡើយ។

២៤. ទាក់ទងនឹងហេតុផលទីមួយ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ខុសពីលក្ខន្តិកៈតុលាការ SCSL។ ខណៈដែលពាក្យពេចន៍នៃលក្ខន្តិកៈតុលាការ SCSL អាចយកមកធ្វើជាការចង្អុលបង្ហាញថា រដ្ឋអាជ្ញាគឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការកំណត់ថា តើបុគ្គលមាន ឬ មិនមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. គ្រាន់តែចែងនៅក្នុង មាត្រា ១៦ (ទាក់ទងនឹងតួនាទីរបស់សហព្រះរាជអាជ្ញា) ថា "រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាពីរនាក់... ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និង ធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ"។ ប្រសិនបើពាក្យថា "មេដឹកនាំជាន់ខ្ពស់" ឬ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានប្រើក្នុងគោលបំណងគ្រាន់តែជាគោលការណ៍ណែនាំ សម្រាប់ឆន្ទានុសិទ្ធិនៃការចោទប្រកាន់នោះ ពាក្យពេចន៍ទាំងនេះ ប្រាកដជាត្រូវបានដាក់បញ្ចូលទៅក្នុងបទប្បញ្ញត្តិ *នេះ* ជាក់ជាមិនខាន ជាជាងដាក់បញ្ចូលទៅក្នុងមាត្រាស្តីអំពី "សមត្ថកិច្ច" ជាមួយនឹងលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការផ្សេងៗទៀតនោះ[69]។

---

[66] មាត្រា ៥(៣) ចែងថា៖ "សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និង មិនទទួលយក ឬ ស្វែងរកការណែនាំពីរដ្ឋាភិបាល ឬ ប្រភពណាមួយផ្សេងទៀតបានឡើយ។ ប៉ុន្តែ គេត្រូវយល់ថា វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត..."។

[67] មាត្រា ៦(៣) ចែងថា៖ "សហព្រះរាជអាជ្ញា ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និង មិនទទួលយក ឬ ស្វែងរកការណែនាំពីរដ្ឋាភិបាល ឬ ប្រភពណាមួយផ្សេងទៀតឡើយ។ ប៉ុន្តែត្រូវយល់ថា វិសាលភាពនៃការចោទប្រកាន់ គឺកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត..."។

[68] *រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Brima និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលដីកា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ២៨៣។

[69] មាត្រា ២ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

២៥. លើសពីនេះទៀត ការដាក់កម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. មិនដាក់កម្រិតលើឯករាជ្យភាពរបស់ ក.ស.ព. ឬ ក.ស.ច.ស. ច្រើនជាងការដាក់កម្រិតយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. ឡើយ។ ដូចដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេច សហព្រះរាជអាជ្ញាមិនមានអំណាចឆន្ទានុសិទ្ធិកំណត់ថានរណានឹងត្រូវចោទប្រកាន់ឡើយ៖ "អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ពុំមានអំណាចឆន្ទានុសិទ្ធិដែលសហព្រះរាជអាជ្ញាត្រូវយកទៅអនុវត្តនោះទេ...។ នៅពេលណាដែលមានការទាញសេចក្តីសន្និដ្ឋានថា មាន 'ហេតុផលដែលនាំឲ្យជឿបានថា ឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក. ត្រូវបានប្រព្រឹត្តឡើង' នៅពេលនោះ សហព្រះរាជអាជ្ញាមានកាតព្វកិច្ចបើកកិច្ចស៊ើបសួរ តាមរយៈការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ"[70]។

២៦. ទាក់ទងនឹងហេតុផលទីពីរ អង្គបុរេជំនុំជម្រះជាអ្នកដែលមានសមត្ថកិច្ចត្រឹមត្រូវបំផុតក្នុងការសម្រេចថា តើជនត្រូវចោទស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឬយ៉ាងណា ដោយផ្អែកទៅលើដីកាដំណោះស្រាយ នៅមុនពេលការជំនុំជម្រះណាមួយបានកើតឡើង[71]។ អង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការជំនុំជម្រះលើការជំទាស់តវ៉ានឹងយុត្តាធិការរបស់ អ.វ.ត.ក.[72] ដែលអាចកើតមានឡើងជាការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដីកាដំណោះស្រាយ)។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងទទួលបានដីកាដំណោះស្រាយជាមួយនឹងភ័ស្តុតាងគាំទ្រ ដើម្បីអាចឲ្យអង្គបុរេជំនុំជម្រះសម្រេចលើការជំទាស់តវ៉ាផ្នែកយុត្តាធិការនេះបាន។ ផ្ទុយទៅវិញ នៅឯតុលាការ SCSL មិនមានកិច្ចស៊ើបសួរ ហើយក៏មិនមានអង្គបុរេជំនុំជម្រះដែលមានយុត្តាធិការដោះស្រាយការជំទាស់តវ៉ានឹងយុត្តាធិការឡើយ។ នៅទីនោះ ជាក់ស្តែង ការសម្រេចទៅលើយុត្តាធិការលើបុគ្គលមិនអាចធ្វើទៅបានឡើយ រហូតទាល់តែបញ្ចប់ការជំនុំជម្រះក្តីដែលចំណាយពេលយូរ និងអស់ថវិកាច្រើន។

[70] ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង មតិយោបល់របស់ចៅក្រម Lahuis និង ចៅក្រម Downing ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ កថាខណ្ឌ ២៣។

[71] អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ការបញ្ចៀសសវនាការ ដោយផ្អែកលើការពុំមានយុត្តាធិការ លើកកម្ពស់រដ្ឋបាលតុលាការឲ្យកាន់តែមានប្រសិទ្ធភាព និង សណ្តាប់ធ្នាប់ល្អ។ *សូមមើល* សាលដីការឿងក្តី ០០១ កថាខណ្ឌ ២៨។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា តួនាទីរបស់អង្គបុរេជំនុំជម្រះនៅក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នា មិនកែប្រែសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ឃ្លានោះមិនមានលក្ខណៈជាយុត្តាធិការឡើយ ប៉ុន្តែប្រការនេះមិនបានអើពើចំពោះតួនាទីរបស់អង្គបុរេជំនុំជម្រះនៅក្នុងការសម្រេចទៅលើការជំទាស់តវ៉ាទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក.។

[72] វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

២៧. ជាចុងក្រោយ នៅឯតុលាការ SCSL មិនមានអ្វីទាក់ទងនឹងយុត្តាធិការលើបុគ្គលរបស់តុលាការ ចែងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និង ប្រទេសសៀរ៉ាឡេអូន ដើម្បីបង្កើត តុលាការ SCSL ឡើយ។ ពាក្យពេចន៍ "បុគ្គលទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុត" មាននិយាយតែនៅក្នុងលក្ខន្តិកៈតុលាការ SCSL ប៉ុណ្ណោះ។ ករណីផ្ទុយគ្នានេះ គឺពិតនៅ អ.វ.ត.ក. ដែលកិច្ចព្រមព្រៀងបានចែងយ៉ាងច្បាស់ថា "អង្គជំនុំជម្រះវិសាមញ្ញមាន *យុត្តាធិការលើរូបបុគ្គល* ទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ..."[73]។ យោងតាមអ្នកសិក្សាស្រាវជ្រាវម្នាក់ នេះ "ប្រហែលជាភ័ស្តុតាងដ៏រឹងមាំបំផុត" ដែលថា ពាក្យពេចន៍របស់ អ.វ.ត.ក. គឺមានលក្ខណៈជាយុត្តាធិការ[74]។

### ខ. សម្ភារៈឯកសារនៃ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា គឺចាំបាច់សម្រាប់កំណត់អត្ថន័យនៃពាក្យថា *មេដឹកនាំជាន់ខ្ពស់ និង ជនដែលទទួលខុសត្រូវខ្ពស់បំផុត*

២៨. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់ថាបុគ្គលណាស្ថិតនៅក្នុងប្រភេទនៃ *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ក៏ដោយ[75] ក៏នៅក្នុងរឿងក្តី ០០៣ ស.ច.ស.អ.ប. បាន កំណត់លក្ខណៈវិនិច្ឆ័យក្នុងការសម្រេចថា តើនរណាម្នាក់ជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ឬ យ៉ាងណា[76]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានយកលក្ខណៈវិនិច្ឆ័យនេះមកអនុវត្តផងដែរនៅក្នុង

---

[73] មាត្រា ២ នៃកិច្ចព្រមព្រៀង (សេចក្តីបញ្ជាក់បន្ថែម)។

[74] Sean Morrison *ពាក្យពេចន៍វិសាមញ្ញនៅក្នុងតុលាការកម្ពុជា៖ ការបកស្រាយពាក្យពេចន៍ដែលមានលក្ខណៈជាការដាក់កម្រិត និង យុត្តាធិការលើបុគ្គលរបស់សាលាក្តីកម្ពុជា* (Extraordinary Language in the Courts of Cambodia: Interpreting the Limiting Language and Personal Jurisdiction of the Cambodian Tribunal) 37 CAP. U. L. REV. 583, 599 (ឆ្នាំ ២០០៩) ។ សាស្ត្រាចារ្យ Jalloh ធ្វើការអះអាងដ៏គួរឱ្យចាប់អារម្មណ៍ថា "ទោះបីជា គេរំពឹងថានឹងធ្វើការចោទប្រកាន់តែលើបុគ្គលមួយចំនួនតូចក៏ដោយ ក៏មាត្រា (១) នៃលក្ខន្តិកៈសាលាក្តីលីបង់ បានដាកទៅប្រើប្រាស់ឃ្លា "ចោទប្រកាន់បុគ្គលដែលមានការទទួលខុសត្រូវ" ដែលប្រការនេះប្រហែលដោយសារមានការពិចារណាលើបទពិសោធន៍ដែលអគ្គលេខាធិការបានជួបប្រទះ អំពីភាពចម្រូងចម្រាសនៃពាក្យការទទួលខុសត្រូវខ្ពស់បំផុត"។ Charles Chernor Jalloh *ការចោទប្រកាន់អ្នកទាំងឡាយដែលមាន "ការទទួលខុសត្រូវខ្ពស់បំផុត"៖ បទពិសោធន៍របស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន* (Prosecuting Those Bearing "Greatest Responsibility": The Lessons of the Special Court of Sierra Leone) 96 MARQ. L. REV. 863, n. 72 (ឆ្នាំ ២០១៣)។

[75] សាលដីការឿងក្តី ០០១ កថាខណ្ឌ ៦២។

[76] សេចក្តីសម្រេចអំពីយុត្តាធិការលើបុគ្គល កថាខណ្ឌ ១៥-១៦។

រឿងក្តី ០០១[77]។ ស.ច.ស.អ.ប. បានទទួលស្គាល់ថា "គ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំងឡាយដែលអាចយកមកអនុវត្តបានដោយផ្ទាល់នៅ អ.វ.ត.ក. ផ្តល់នូវគោលការណ៍ណែនាំអំពីរបៀបដែលលក្ខខណ្ឌតម្រូវទាំងនេះគួរត្រូវបានអនុវត្តឡើយ"[78] ប៉ុន្តែ បានយល់ឃើញថា "សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំនៅក្នុង "បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ""[79]។ គាត់បានពិចារណាជាចម្បងទៅលើយុត្តិសាស្ត្ររបស់សាលាក្តី ICTY ក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យដែលគាត់នឹងយកមកអនុវត្ត នៅពេលពិចារណាថា តើលោក មាស មុត ជា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* ឬយ៉ាងណានោះ[80]។ វិធីសាស្ត្រនេះ គឺមិនត្រឹមត្រូវ។

២៩. ប្រសិនបើ ស.ច.ស.អ.ប. បានយល់ឃើញថា អត្ថន័យនៃពាក្យថា *មេដឹកនាំជាន់ខ្ពស់* ឬ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* គឺមិនច្បាស់លាស់នោះ គាត់គួរតែបានអនុវត្តវិធីសាស្ត្រនៃការបកស្រាយច្បាប់ដែលមានចែងនៅក្នុងអនុសញ្ញា VCLT ហើយ។ វិធីសាស្ត្រនេះនឹងនាំគាត់ទៅរកការពិចារណាលើគោលបំណងរបស់អ្នកធ្វើសេចក្តីព្រាង[81]។ ជំនួសវិញ គាត់បានងាកទៅរក "បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ"[82]។ គាត់បានដកស្រង់ មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សម្រាប់សិទ្ធិអំណាចរបស់គាត់ក្នុងការអនុវត្តវិធីសាស្ត្រនេះ[83]។

---

[77] *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ២២-២៥។

[78] សេចក្តីសម្រេចអំពីយុត្តាធិការលើបុគ្គល កថាខណ្ឌ ១៥។

[79] *ដូចខាងលើ* ដែលដកស្រង់មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[80] *ដូចខាងលើ* កថាខណ្ឌ ១៥។

[81] ពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" គឺមិនច្បាស់លាស់ ពីព្រោះពាក្យទាំងនេះ គឺជាពាក្យដែលមានន័យធៀប។ ដោយសារតែពាក្យពេចន៍សាមញ្ញនៃកិច្ចព្រមព្រៀង ដោយពិចារណាក្នុងបរិបទ និង ដោយគិតពីកម្មវត្ថុ និងគោលបំណងនោះ (មាត្រា ៣១(១) នៃអនុសញ្ញា VCLT) គឺមិនច្បាស់លាស់ ស.ច.ស.អ.ប. គួរតែបានពិចារណាទៅលើការងាររៀបចំកិច្ចព្រមព្រៀង និង កាលៈទេសៈនៃការបង្កើតកិច្ចព្រមព្រៀងនេះ ស្របតាមមាត្រា ៣២ នៃអនុសញ្ញា VCLT។

[82] សេចក្តីសម្រេចអំពីយុត្តាធិការលើបុគ្គល កថាខណ្ឌ ១៥។

[83] មាត្រា ២៣ថ្មី ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់... ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

៣០. មាត្រា ២៣ថ្មី អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីនៅកម្រិតអន្តរជាតិ នៅពេលពួកគាត់ប្រឈមនឹងភាពមិនច្បាស់លាស់ចំពោះការបកស្រាយ "នីតិវិធីដែលនៅជាធរមាន"។ មាត្រានេះ មិនបានអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការបកស្រាយយុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក. ដែលជាបញ្ហាផ្នែកអង្គសេចក្តី ជាជាងបញ្ហាផ្នែកនីតិវិធី ដោយពិចារណាលើយុត្តិសាស្ត្រអន្តរជាតិឡើយ។ លើសពីនេះទៀត វិធីសាស្ត្រនេះគឺមិនសមហេតុផល។ សាលាក្តី ICTY និង សាលាក្តីអន្តរជាតិផ្សេងៗទៀត មិនមែនបង្កើតឡើង ដោយមានយុត្តាធិការលើបុគ្គលដូចគ្នានឹង អ.វ.ត.ក. ឡើយ។ យុត្តាធិការរបស់សាលាក្តីនីមួយៗ ត្រូវបានពិចារណាដោយគិតពីបរិបទដែលសាលាក្តីនេះត្រូវបានបង្កើតឡើង។ ការពិចារណាទៅលើយុត្តាធិការរបស់សាលាក្តី ICTY មិនបានជួយនៅក្នុងការកំណត់គោលបំណងនៃយុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក. ឡើយ។ គោលបំណងរបស់អ្នកធ្វើសេចក្តីព្រាង បង្ហាញថា ការបកស្រាយដ៏សមហេតុផលបំផុតទៅលើពាក្យពេចន៍ទាំងនោះគឺថា *មេដឹកនាំជាន់ខ្ពស់* គឺជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង សមាជិកជាន់ខ្ពស់នៃគណៈកម្មាធិការមជ្ឈិម[84] ហើយ *ជនដែលទទួលខុសត្រូវខ្ពស់បំផុត* មានន័យថា នរណាម្នាក់ដែលយ៉ាងហោចណាស់ មានការទទួលខុសត្រូវដូចជាឌុច[85]។ សម្ភារៈឯកសារនេះ គឺចាំបាច់សម្រាប់បញ្ជាក់ការបកស្រាយនេះ។

---

[84] យោងតាម David Scheffer ដែលបានចូលរួមក្នុងកិច្ចចរចា ក្នុងនាមជាឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិក សម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម "ការប៉ាន់ប្រមាណដ៏ត្រឹមត្រូវមួយអំពីរបៀបដែលយុត្តាធិការលើបុគ្គលវិវត្តន៍នៅដើមឆ្នាំ ១៩៩៩ នឹងកំណត់អត្តសញ្ញាណ កែ ពក តា ម៉ុក ខៀវ សំផន អៀង សារី នួន ជា [sic] និង អៀង ធីរិទ្ធ ហើយឆាប់ៗខាងមុខនេះ នឹងរួមបញ្ចូលទាំង កាំង ហ្គេកអ៊ាវ (ហៅ "ឌុច") ដ៏ល្បីឈ្មោះម្នាក់ នៅពេលគេរកឃើញថាគាត់នៅរស់ និង ជាប់ឃុំឃាំងក្នុងប្រទេសកម្ពុជាកាលពីពាក់កណ្តាលឆ្នាំ ១៩៩៩"។ David Scheffer *ប្រវត្តិនៃការចរចាអំពីយុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក.* (The Negotiatio History of the ECCC's Personal Jurisdiction) CAMBODIA TRIBUNAL MONITOR ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ទំព័រ ២។

[85] នៅពេល ឌុច បានចេញមុខជាសាធារណៈនៅក្នុងខែមេសា ឆ្នាំ ១៩៩៩ និង ត្រូវបានឃុំខ្លួននៅក្នុងតុលាការយោធានៅក្នុងខែឧសភា ឆ្នាំ ១៩៩៩ ឃ្លាថា "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានដាក់បន្ថែមទៅក្នុងការពិភាក្សាអំពីយុត្តាធិការរបស់ អ.វ.ត.ក. ដើម្បីធានាថា ឌុច អាចត្រូវបានចោទប្រកាន់ដោយតុលាការណាមួយដែលបង្កើតឡើងនាពេលអនាគត ទោះបីជាគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ក៏ដោយ។ *សូមមើល* Stephen Heder *យុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់" ខ្មែរក្រហម និង អ្នកផ្សេងទៀតដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និង ការវិវត្តថ្មីៗ* (The Personal Jurisdiction of the Extraordinary Chambers in the Courts of Cambodia as Regards Khmer Rouge "Senior Leaders" and Others "Most Responsible" for Khmer Rouge Crimes: A History and Recent Developments) ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១២ ("សៀវភៅរបស់លោក Heder *យុត្តាធិការលើបុគ្គល*") ទំព័រ ២៧។ Steve Heder *ប្រទេសកម្ពុជា ណាហ្ស៊ីអាល្លឺម៉ង់ និង សហភាពសូវៀតស្តាលីន៖ ចេតនា ផ្តាច់ការ*

៣១. អតីតអ្នកស៊ើបអង្កេត/អ្នកវិភាគនៃ ក.ស.ព. និង ក.ស.ច.ស.[86] Stephen Heder ផ្តល់នូវការបកស្រាយមួយអំពីគោលបំណងរបស់អ្នកធ្វើសេចក្តីព្រាងចំពោះអត្ថន័យនៃពាក្យថា *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត*[87]។ មេធាវីការពារក្តីយល់ឃើញថា ការវិភាគរបស់លោក Heder គឺខ្វះចន្លោះ និង មិនមែនជាកម្មវត្ថុនៃការពិនិត្យឡើងវិញឲ្យបានពេញលេញឡើយ ដោយសារសម្ភារៈឯកសារភាគច្រើនដែលគាត់យកមកធ្វើជាសំអាងនោះ គឺមិនអាចឲ្យសាធារណជនរកមើលបាន និង មិនមាននៅ អ.វ.ត.ក. ឡើយ[88]។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងនឹងសំណើនេះ យោងតាមលោក Heder:

> អតីតអគ្គលេខាធិការរង អ.ស.ប. ទទួលបន្ទុកកិច្ចការច្បាប់ លោក Hans Corell ដែលបានដើរតួយ៉ាងសំខាន់ក្នុងការចរចាបង្កើត អ.វ.ត.ក. បានថ្លែងទៅកាន់បណ្តាញសារព័ត៌មានផងដែរ អំពីខ្លឹមសារនៃកិច្ចចរចាសម្រាប់ដំណើរការបច្ចុប្បន្ន

---

*និយម មុខងារនិយម និង នយោបាយនៃការទទួលខុសត្រូវ* (Cambodia, Nazi Germany and the Stalinist Soviet Union: Intentionality, Totalitarianism, Functionalism and the Politics of Accountability) (សេចក្តីព្រាងសម្រាប់ការធ្វើបទបង្ហាញនៅវិទ្យាស្ថានប្រវត្តិសាស្ត្រអាល្លឺម៉ង់ (German Historical Institute) ទីក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៣) ទំព័រ ៥៣។ ដូច្នេះ ពាក្យថា "ទទួលខុសត្រូវខ្ពស់បំផុត" គឺមានចេតនាសំដៅទៅលើ ឌុច។ ទោះបីជាអ្នកធ្វើសេចក្តីព្រាងហាក់ដូចជាមានគោលបំណងជាក់លាក់សំដៅលើ ឌុច នៅពេលពួកគាត់បានបន្ថែមពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ទៅក្នុងអត្ថបទច្បាប់ក៏ដោយ ក៏ពាក្យនេះមិនអាចត្រូវបានកំណត់និយមន័យយ៉ាងសាមញ្ញថាជា ឌុច ដោយគ្មានការប្រឈមទៅនឹងការរិះគន់ចំពោះ អ.វ.ត.ក. ថាជាប់ពាក់ព័ន្ធនឹងយុត្តិធម៌រើសអើងឡើយ។ ទោះបីជាយ៉ាងនេះក្តី ឌុច អាចត្រូវបានគេយកមកធ្វើជាចំណុចគោល៖ ដើម្បីចាត់ទុកថាជា ជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" បុគ្គលនោះត្រូវតែយ៉ាងហោចណាស់មានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដូចជា ឌុច។

[86] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ [redacted]។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពល ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ ឯកសារ A121។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស លិខិតរបស់ ក.ស.ច.ស. ផ្ញើជូនមេធាវីការពារក្តី សំណើសុំព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០០៨ ឯកសារ A121/I ទំព័រ ១។

[87] សៀវភៅរបស់លោក Heder *យុត្តាធិការលើបុគ្គល*។

[88] *សូមមើល* លិខិតពីមេធាវីការពារក្តី ផ្ញើជូនលោក Heder ស្នើសុំប្រគល់សម្ភារៈពាក់ព័ន្ធនឹងយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០១៥។

របស់ អ.វ.ត.ក....។ នៅក្នុងការបញ្ជូនបន្តទៅ Luc Reydams និង អ្នកផ្សេងទៀត eds. រដ្ឋអាជ្ញាអន្តរជាតិ (Oxford: Oxford University Press, 2012) **ឯកអគ្គរដ្ឋទូត Corell ... បានស្នើឡើងថា បណ្ណសារ អ.ស.ប. គួរតែបើកចំហ ដើម្បីលាតត្រដាងអំពីដំណើរការនៃការចរចា** (សារអេឡិចត្រូនិករបស់ Hans Corell ផ្ញើជូនអ្នកនិពន្ធ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១២)[89]។

លោក Heder លើកឡើងបន្ថែមទៀតថា៖

**ខ្ញុំកត់សម្គាល់ថា គ្រប់ករណីទាំងអស់ អ.ស.ប. គួរតែមានលទ្ធភាពសម្រេចតាមឆន្ទានុសិទ្ធិ ក្នុងការដាក់ឱ្យ អ.វ.ត.ក. ប្រើប្រាស់បានជាផ្លូវការនូវរាល់កំណត់ហេតុពាក់ព័ន្ធទាំងអស់នៃកិច្ចចរចា រួមជាមួយនឹងការបញ្ជាក់អំពីយថាភាពនៃកំណត់ហេតុទាំងនោះផងដែរ** អនុលោមតាមមាត្រា ២១ នៃអនុសញ្ញា ស្តីពីបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៤៦[90]។

៣២. សម្ភារៈឯកសារដែលមាននៅក្នុងបណ្ណសារ អ.ស.ប. មានរៀបរាប់ជាបញ្ជីនៅលើប្រព័ន្ធអ៊ីនធឺណិត[91] ប៉ុន្តែមានតែសម្ភារៈឯកសារតិចតួចប៉ុណ្ណោះដែលអាចទាញយកមកប្រើប្រាស់បាន[92]។ សម្ភារៈ ឯកសារនៅសល់ទាំងប៉ុន្មានទៀត ត្រូវតែមានការស្នើសុំ និង ទិញពី អ.ស.ប.។ សម្ភារៈឯកសារដែលមានជាប់ពាក់ព័ន្ធច្រើនទៅនឹងកិច្ចចរចា មានចំណាត់ថ្នាក់ឯកសារជាឯកសារ “សម្ងាត់បំផុត”[93]។ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលត្រួតពិនិត្យទៅលើក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកសាលាក្តីខ្មែរក្រហម គួរតែមានបណ្ណសារនេះផ្ទាល់របស់ខ្លួនផងដែរ។

៣៣. ដោយសារតែសម្ភារៈឯកសារភាគច្រើនដែលបានស្នើសុំនេះ មិនអាចរកមើលបានជាសាធារណៈនៅពេលបច្ចុប្បន្ននេះ មេធាវីការពារក្តីមិនមានលទ្ធភាពធ្វើការស្នើសុំឯកសារជាក់លាក់ ឬ ដាក់កម្រិតសំណើសុំនេះឱ្យនៅតិចតួចបានឡើយ។ ប្រការដែលមេធាវីការពារក្តីមិនស្នើសុំឯកសារជាក់

---

[89] សៀវភៅរបស់លោក Heder *យុត្តាធិការលើបុគ្គល* ជើងទំព័រ ១ (សេចក្តីបញ្ជាក់បន្ថែម)។

[90] *ដូចខាងលើ* (សេចក្តីបញ្ជាក់បន្ថែម)។

[91] *អាចរកមើលបាននៅលើគេហទំព័រ* https://archives.un.org។

[92] មេធាវីការពារក្តីបានទាញយករួចហើយនូវសម្ភារៈទាំងអស់ដែលអាចទាញយកមកប្រើប្រាស់បាន និង ដែលជាសម្ភារៈពាក់ព័ន្ធ។

[93] *សូមមើល* ឧបសម្ព័ន្ធ ដែលរាយឈ្មោះសំណុំឯកសារនៅក្នុងបណ្ណសារ អ.ស.ប. ដែលជាប់ពាក់ព័ន្ធយ៉ាងច្រើនបំផុត។

លាក់ពីបណ្ណសារនោះ មិនគួររារាំងសហចៅក្រមស៊ើបអង្កេតពីការយក និង ដាក់ចូលទៅក្នុងសំណុំរឿងនូវសម្ភារៈឯកសារ *ទាំងអស់* ទាក់ទងនឹងការបង្កើត អ.វ.ត.ក. នោះឡើយ។ សម្ភារៈឯកសារទាំងអស់នេះ នឹងបង្ហាញជាភ័ស្តុតាងដ៏ប្រសើរបំផុតអំពីគោលបំណងរបស់ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា។

៣៤. ការយកសម្ភារៈឯកសារដែលស្នើសុំនេះ និង ការដាក់បញ្ចូលសម្ភារៈឯកសារទាំងនេះទៅក្នុងសំណុំរឿង មិនធ្វើឱ្យខូចប្រយោជន៍ភាគីណាមួយឡើយ។ សម្ភារៈឯកសារដែលស្នើសុំនេះ នឹងជួយដល់សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះ និង ភាគីទាំងអស់ក្នុងការកំណត់អត្ថន័យនៃពាក្យ *មេដឹកនាំជាន់ខ្ពស់* និង *ជនដែលទទួលខុសត្រូវខ្ពស់បំផុត*។ ការផ្តល់នូវព័ត៌មានដែលស្នើសុំ នឹងជួយលើកកម្ពស់តម្លាភាពផងដែរ[94]។ សាធារណជនមានផលប្រយោជន៍ក្នុងការទទួលបានសម្ភារៈ ឯកសារនេះ ហើយនៅពេលនេះ អ.វ.ត.ក. ត្រូវបានបង្កើតឡើងរួចហើយ ដូច្នេះមិនមានហេតុផលណាមួយដែលមិនអាចដាក់សម្ភារៈនេះឲ្យមើលជាសាធារណៈបាននោះឡើយ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីគោរពស្នើសុំសហចៅក្រមស៊ើបអង្កេតមេត្តា៖ **យក** សម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក. និង ការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង **ដាក់** សម្ភារៈឯកសារនេះទៅក្នុងសំណុំរឿង។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១០** ខែ**វិច្ឆិកា** ឆ្នាំ **២០១៥**

សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| **អាង ឧត្តម** | Michael G. KARNAVAS |

[94] ក្នុងអំឡុងកិច្ចចរចា ឯកអគ្គរដ្ឋទូត Corell បានសង្កត់ធ្ងន់លើសារៈសំខាន់នៃតម្លាភាព ក្នុងគោលបំណងដើម្បីបញ្ចៀសនូវ "*ការយល់ខុស និង ការបកស្រាយខុសនូវគោលជំហររបស់ អ.ស.ប.*" (*សូមមើល* Hans Corell កំណត់សម្គាល់ផ្ញើជូន Iqbal Riza "*ការជំនុំជម្រះក្តីខ្មែរក្រហម*" ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០០២) និង បានស្នើឡើងកាលពីចុងឆ្នាំ ២០១២ ឲ្យបើកបណ្ណសារ អ.ស.ប. ដើម្បីលាតត្រដាងកិច្ចខិតខំប្រឹងប្រែងរបស់ អ.ស.ប. ដើម្បីធានាថា អ.វ.ត.ក. ត្រូវបានរៀបចំឡើងនៅក្នុងលក្ខណៈមួយដែលគោរពបទដ្ឋានយុត្តិធម៌អន្តរជាតិ។ *សូមមើល* LUC REYDAMS និង អ្នកផ្សេងទៀត EDS., រដ្ឋអាជ្ញាអន្តរជាតិ (INTERNATIONAL PROSECUTORS) (Oxford University Press 2012)។